១សាំយូអែល៣:១-៥:១០

# ជំពូក ៣

## *ណាទចនា ការត្រាស់ហៅលោកសាំយូអែល*

ការត្រាស់ហៅលោកសាំយូអែល ច្រើនតែគេយកមកប្រើក្នុងមេរៀនសម្រាប់បង្ហាត់បង្រៀនដល់កុមារ។ ប៉ុន្តែ រឿងនេះមិនមែនជារឿងសម្រាប់កុមារតែមួយមុខប៉ុណ្ណោះទេ ពោលគឺបុរសស្ត្រីដែលមានវ័យកម្រិតណាក៏អាចយកមកអនុវត្តបានដែរ។ សម័យលោកសាំយូអែល ជាគ្រាអន្តរកាលចន្លោះរបបទេវាធិបតេយ្យ និងរបបរាជានិយម។ ក្នុងរបបទេវាធិបតេយ្យ សង្ឃជាអ្នកសម្រេចក្តី រីឯរបបរាជាធិបតេយ្យវិញស្តេចជាអ្នកសម្រេចរឿងក្តីនៅក្នុងនគរ។

ព្រះជាម្ចាស់ត្រាស់ហៅលោកសាំយូអែលចំនួនបួនដង។ លើកទីមួយ និងលើកទីពីរ គឺនៅក្នុង៧។ ការនោះជាការត្រាស់ហៅលោកសាំយូអែល អោយទទួលសេចក្តីសង្គ្រោះ។ ឯការត្រាស់ហៅលើកទីបី និងលើកទីបួននៅក្នុង១០។ ការត្រាស់ហៅនេះ គឺហៅអោយលោកសាំយូអែលចូលមកបម្រើទ្រង់។ ការដែលលោកសាំយូអែល ព្រមធ្វើតាមការត្រាស់ ញ៉ាំងអោយមានការប្តូរផ្លាស់នៅក្នុងទម្រង់រដ្ឋាភិបាលនៃសាសន៍អ៊ីស្រាអែល។ រាជ្យរបស់ពួកចៅហ្វាយបានកន្លងផុតទៅហើយ។ រីឯព្រះជាម្ចាស់វិញ ទ្រង់មិនមានបន្ទូលតាមរយៈសង្ឃណាដែរ។ ពីពេលនេះទៅ ទ្រង់ត្រាស់ហៅបុគ្គល

ម្នាក់ ដើម្បីធ្វើជាសង្ឃផង ធ្វើជាហោរាផង។ បុគ្គលនោះគឺលោកសាំយូអែល។ ក្នុងនាមលោកជាហោរារបស់ព្រះជាម្ចាស់ លោកបានតែងតាំងស្តេចពីរអង្គ គឺស្តេចសូល និងក្សត្រដាវីឌ។ ប៉ុន្តែ ទោះលោកបានតែងតាំងស្តេចឡើងគ្រងរាជ្យក៏ដោយ ព្រះជាម្ចាស់មិនដែលអនុញ្ញាតអោយស្តេចនិយាយជំនួសព្រះអង្គទេ។ ព្រះអង្គបង្គាប់អោយហោរារបស់ទ្រង់និយាយទៅកាន់មនុស្សលោកជំនួសព្រះអង្គ។

> **រីឯសាំយូអែល ក្មេងនោះ ក៏ធ្វើការងារថ្វាយព្រះយេហូវ៉ា នៅចំពោះមុខអេលី ក្នុងគ្រានោះ ព្រះបន្ទូលនៃព្រះយេហូវ៉ាកាន់តែក្រទៅ ឯការជាក់ស្តែងក៏មិនសូវមានជាញឹកញយដែរ (១សាំយូអែល៣:១)។**

នៅក្នុងខនេះសម្តែងថា សាំយូអែលជាក្មេង។ បើតាមខ្ញុំយល់ លោកសាំយូអែលជាយុវជនជំទង់ហើយ។

ម្យ៉ាងវិញទៀត ខខាងលើសម្តែងថា នៅពេលដែលព្រះជាម្ចាស់ត្រាស់ហៅលោកសាំយូអែលអោយមកទទួលងារជាហោរា ព្រះបន្ទូលរបស់ព្រះយេហូវ៉ាកាន់តែក្រទៅ។ ត្រង់នេះមានន័យថា ព្រះអម្ចាស់មានបន្ទូលទៅកាន់បណ្តាជនតាមរយៈហោរារបស់ទ្រង់វិញ។ ឯហោរារបស់ទ្រង់ ដំបូងបង្អស់គឺ លោកសាំយូអែល។

> **២ នៅគ្រានោះឯង មានពេល១ដែលអេលីដេកនៅដំណេករបស់**
> **លោក (សម័យនោះភ្នែកលោកបានចាប់តាំងងងឹតទៅ មើលអ្វីមិន**
> **ឃើញឡើយ) ៣ ហើយសាំយូអែលក៏ដេក នៅក្នុងព្រះវិហារព្រះយេ**
> **ហូវ៉ាដែរ ជាកន្លែងដែលមានហឹបនៃព្រះ ក្នុងកាលដែលចង្កៀង**
> **នៃព្រះមិនទាន់រលត់នៅឡើយ (១សាំយូអែល៣:២-៣)។**

នាទីរបស់សង្ឃ គឺត្រូវដុតចង្កៀងអោយនៅភ្លឺក្នុងរោងឧបោសថជានិច្ច។ ចំណែកសង្ឃអេលីវិញ លោកមានវ័យចាស់ជរាណាស់ហើយ ភ្នែករបស់លោកមើលមិនឃើញ ឯចង្កៀងរបស់លោក ក៏ហៀបនឹងរលត់ដែរ។

> **៤ នោះព្រះយេហូវ៉ាទ្រង់ហៅមកសាំយូអែល ហើយសាំយូអែលតប**
> **ថា ប្របាទ ៥ រួចក៏រត់ទៅឯអេលីសួរថា ខ្ញុំមកហើយ លោកមាន**
> **ការអី តែអេលីឆ្លើយទៅថា អញគ្មានហៅឯងទេ ចូរទៅដេកវិញ**
> **ទៅ សាំយូអែលក៏ទៅដេកវិញ (១សាំយូអែល៣:៤-៥)។**

នៅពេលដែលលោកសាំយូអែលមកសួរបញ្ជាក់ដល់សង្ឃអេលី សង្ឃអេលីស្មានថា យុវជនសាំយូអែលដេកមមើរ បានជាលោកបង្គាប់អោយសាំយូអែលត្រឡប់ទៅដេកវិញទៅ។

**នោះព្រះយេហូវ៉ាទ្រង់ហៅម្តងទៀតថា នែសាំយូអែល រួចសាំយូអែលក្រោកឡើង ទៅឯអេលីសួរថា ខ្ញុំមកហើយ លោកមានការអ្វី តែអេលីឆ្លើយថា កូនអើយ អញគ្មានហៅឯងទេ ចូរទៅដេកវិញទៅ (១សាំយូអែល៣:៦)។**

ការត្រាស់ហៅដល់លោកសាំយូអែលលើកទីមួយនិងលើកទីពីរ គឺជាការត្រាស់ហៅសាំយូអែលអោយទទួលសេចក្តីសង្គ្រោះ។

**ឯសាំយូអែលមិនទាន់ស្គាល់ព្រះយេហូវ៉ានៅឡើយទេ ព្រះបន្ទូលនៃទ្រង់ក៏មិនទាន់បានសំដែងមកឱ្យដឹងដែរ (១សាំយូអែល៣:៧)។**

លោកសាំយូអែលមិនទាន់ស្គាល់ព្រះជាម្ចាស់នៅឡើយទេ។ ព្រះជាម្ចាស់ទ្រង់បានហៅលោក ដើម្បីអោយលោកទទួលសេចក្តីសង្គ្រោះពីទ្រង់។ នៅពេលនេះ ហោរាសាំយូអែលបានឈានមកដល់អាយុដែលចេះទទួលខុសត្រូវខ្លួនឯងហើយ។ ដោយសារសាំយូអែលឈានមកដល់អាយុដែលចេះទទួលខុសត្រូវខ្លួនឯង ព្រះជាម្ចាស់ចង់អោយលោកមានការទទួលខុសត្រូវ ក្នុងការទទួលព្រះអង្គធ្វើជាអង្គសង្គ្រោះរបស់ខ្លួន។ យើងគ្រប់រូបត្រូវសម្រេចចិត្តទទួលសេចក្តីសង្គ្រោះ នៅពេលណាដែលយើងដឹងក្តីពេញបរិបូរ។

**៨រួចព្រះយេហូវ៉ាទ្រង់ហៅម្តងទៀត ជាគំរប់៣ដងថា នែសាំយ៉ូ
អែលអើយ នោះសាំយ៉ូអែលក៏ក្រោកឡើង ទៅឯអេលីសួរថា ខ្ញុំ
មកហើយ លោកមានការអី ដូច្នេះអេលីក៏យល់ឃើញថា គឺជា
ព្រះយេហូវ៉ាហើយ ដែលបានហៅក្មេងនេះ ៩លោកក៏ប្រាប់ដល់
សាំយ៉ូអែលថា ចូរឯងដេកទៅ បើឮសួរហៅម្តងទៀត នោះត្រូវ
ឆ្លើយថា បពិត្រ ព្រះយេហូវ៉ាអើយ សូមទ្រង់មានបន្ទូលមកចុះ
ដ្បិតទូលបង្គំ ជាអ្នកបំរើទ្រង់ ប្រុងស្តាប់ហើយ ដូចេះសាំយ៉ូអែល
បានទៅដេកនៅដំណេកខ្លួនវិញទៅ ១០លំដាប់នោះ ព្រះយេហូវ៉ា
ទ្រង់យាងមកឈរ ហៅដូចជាជាន់មុនថា សាំយ៉ូអែល នែ សាំយ៉ូ
អែលអើយ នោះសាំយ៉ូអែលទូលឆ្លើយថា សូមទ្រង់មានបន្ទូលមក
ចុះ ដ្បិតទូលបង្គំ ជាអ្នកបំរើទ្រង់ប្រុសស្តាប់ហើយ (១សាំយ៉ូអែល
៣:៨-១០)។**

ក្នុងខខាងលើសម្តែងអំពីការត្រាស់ហៅលើកទីបីនិងលើកទីបួន ដល់លោកសាំយ៉ូអែល។ ការត្រាស់ហៅលើកនេះ គឺហៅអោយលោកចូលមកបម្រើទ្រង់។

**១១ដូច្នេះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញរៀបនឹងធ្វើ
ការ១នៅក្នុងសាសន៍អ៊ីស្រាអែល ដែលនឹងធ្វើឱ្យខ្ទរដល់ត្រចៀក**

**ទាំងសងខាង នៃអស់អ្នកណាដែលឮ [12]នៅថ្ងៃនោះ អញនឹងសំរេចទាស់នឹងអេលី តាមគ្រប់ទាំងការដែលអញបាននិយាយពីពួកគ្រួលោកហើយ ចាប់តាំងពីដើម ដរាបដល់ចុងផង (១សាំយូអែល៣:១១-១២)។**

នៅពេលដែលព្រះជាម្ចាស់ទ្រង់ធ្វើអ្វីមួយ ទ្រង់ធ្វើដូចដែលទ្រង់តែងតែធ្វើពីដើមរៀងមក។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ បទទំនាយនានាសុទ្ធតែសរសេរនៅក្នុងគ្រាអតីតកាល ប៉ុន្តែ រឿងនេះត្រូវកើតឡើងនៅក្នុងពេលអនាគត។ ព្រះអង្គមានបន្ទូលអំពីហេតុការណ៍ដែលមិនទាន់កើតនៅឡើយ ហាក់ដូចជាបានកើតរួចទៅហើយ។ នៅពេលព្រះអម្ចាស់សន្យាថា មានអ្វីនឹងកើតឡើង រឿងនោះពិតជាកើតឡើងយ៉ាងដូច្នោះមែន។ ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកសាំយូអែលថា ទ្រង់នឹងតាំងសេចក្ដីជំនុំជំរះទាស់ជាមួយនឹងលំនៅដ្ឋានរបស់សង្ឃអេលី។

នៅក្នុងពេលនេះ យុវជនសាំយូអែលមានភក្ដីភាពយ៉ាងខ្លាំង ជាមួយនឹងសង្ឃអេលី ដែលជាចៅហ្វាយរបស់លោក។ ទោះបីកូនប្រុសរបស់លោកអេលីធ្វើអោយលោកបាក់មុខយ៉ាងណាក៏ដោយ យុវជនសាំយូអែលមិនដែលមាក់ងាយ មិនបានបន្ថោកបន្ទាបចៅហ្វាយរបស់លោកទេ។ នៅពេលណាដែលលោកដឹងរឿងអ្វីមួយ លោកតែងតែទៅជួបចៅហ្វាយរបស់លោក រួចហើយជម្រាបលោកអំពីគ្រប់រឿងទាំងអស់ ដែលព្រះជាម្ចាស់មានបន្ទូលមកកាន់លោក។ រឿងនេះ ទាក់ទងជាមួយនឹងយើងដែលជាអ្នកបម្រើ

ព្រះអង្គ នៅក្នុងគ្រាបច្ចុប្បន្ននេះដែរ។ បើលោកអ្នកបម្រើព្រះអង្គដោយស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នរណាម្នាក់ លោកអ្នកចាំបាច់ត្រូវមានភក្តីភាពចំពោះបុគ្គលនោះ។ លោកអ្នកមិនអាចនិយាយថា ខ្ញុំមានភក្តីភាពចំពោះព្រះគ្រិស្ត ប៉ុន្តែ ខ្ញុំស្អប់ដល់អ្នកទទួលខុសត្រូវពីលើខ្ញុំទេ។ បើលោកអ្នកនិយាយយ៉ាងដូច្នោះមែន លោកអ្នកពិតជាមិនមានភក្តីភាពចំពោះព្រះអម្ចាស់យេស៊ូវគ្រិស្ត ជាពិតប្រាកដ។ ការក្បត់ចៅហ្វាយរបស់ខ្លួន ដែលជាមនុស្សលោក គឺជាសញ្ញាបញ្ជាក់ថា នៅក្នុងចិត្តរបស់លោកអ្នកពិតជាក្បត់ព្រះអម្ចាស់យេស៊ូវគ្រិស្តមែនហើយ។ បច្ចុប្បន្ននេះ យើងត្រូវការមនុស្សដែលមានភក្តីភាពចំពោះអ្នកដឹកនាំខ្លាំងណាស់។

> **ក្រោយមក ព្រះយេហូវ៉ាទ្រង់តែងលេចមកនៅត្រង់ស៊ីឡូរទៀត ដ្បិតបានសំដែងមកឱ្យសាំយូអែលស្គាល់នៅត្រង់ស៊ីឡូរ ដោយសារព្រះបន្ទូលនៃទ្រង់ ហើយពាក្យសំដីរបស់សាំយូអែលក៏ឮ ផ្សាយទៅដល់សាសន៍អ៊ីស្រាអែលទាំងអស់គ្នា (១សាំយូអែល៣:២១)។**

តើព្រះជាម្ចាស់បើកសម្តែងអោយយុវជនសាំយូអែលដឹងយ៉ាងដូចម្តេច? ព្រះអង្គបើកសម្តែងអោយយុវជនសាំយូអែលដឹងដោយសារព្រះបន្ទូលរបស់ទ្រង់។ បច្ចុប្បន្ននេះ ក៏ដូច្នោះដែរ ព្រះអង្គតែងតែមានបន្ទូលមកកាន់យើងទាំងអស់គ្នាតាមរយៈព្រះបន្ទូលព្រះអង្គ ដែលបានសរសេរឡើងជាភាសាមនុស្សជាតិ។ នៅពេលលោកអ្នក

បងប្អូនអានព្រះបន្ទូលរបស់ព្រះអង្គដោយចង់ដឹងព្រះហឫទ័យបំណងរបស់ព្រះ ព្រះវិញ្ញាណបរិសុទ្ធពិតជាបំភ្លឺសតិបញ្ញារបស់យើង អោយយើងយល់សេចក្ដីនានា ដែលបានសរសេរលើទំព័រព្រះគម្ពីរ។ យើងអាចស្គាល់ដល់ព្រះអម្ចាស់ដែលជាព្រះនៃស្ថានសួគ៌ ព្រមទាំងទទួលជីវិតអស់កល្បជានិច្ចដោយសារព្រះបន្ទូលរបស់ទ្រង់។

# ជំពូក ៤

***ខាទចនា សេចក្តីជំនុំជំរះរបស់ព្រះមកលើកូនប្រុសរបស់សង្ឃអេលី***

នៅក្នុងជំពូក៤ យើងឃើញថាពួកសាសន៍អ៊ីស្រាអែលនាំគ្នាចូលទៅច្បាំងជាមួយនឹងសាសន៍ភីលីស្ទីន ដោយមិនបានសួរយោបល់ដល់លោកសាំយូអែល ដែលជាហោរារបស់ព្រះទេ។ ដោយសារមូលហេតុនោះហើយ បានជាសាសន៍នេះទទួលបរាជ័យយ៉ាងដំណំ។ មុននឹងចូលទៅក្នុងសមរភូមិ ពួកសាសន៍អ៊ីស្រាអែលនាំគ្នាសែងយកហឹបសញ្ញារបស់ព្រះ ដោយជឿថា ហឹបសញ្ញានោះអាចនាំអោយគេមានជ័យជំនះនៅក្នុងសង្គ្រាមបាន។ កិរិយារបស់សាសន៍អ៊ីស្រាអែលត្រង់ចំណុចនេះ សម្តែងអោយឃើញថា សាសន៍អ៊ីស្រាអែលមានជំនឿទៅលើពាក្យទំនឹមទំនៀមរបស់សាសន៍ដទៃដែលគេជឿថា នៅលើលោកនេះ ពិតជាមានវត្ថុស័ក្តសិទ្ធិ។ ថ្វីដ្បិតគេយល់ថា ហឹបសញ្ញារបស់ព្រះជាម្ចាស់ជាវត្ថុស័ក្តសិទ្ធិ សាសន៍អ៊ីស្រាអែលចាញ់សង្គ្រាម ដែលបណ្តាលអោយសាសន៍ភីលីស្ទីនដណ្តើមយកហឹបសញ្ញាបាន។ ឯកូនប្រុសទាំងពីររូបរបស់សង្ឃអេលី ដែលត្រូវជាសង្ឃរបស់សាសន៍អ៊ីស្រាអែល ត្រូវស្លាប់នៅក្នុងសមរភូមិដែរ។ លុះសង្ឃអេលីឮដំណឹងថា ហឹបសញ្ញារបស់ព្រះយេហូវ៉ា ត្រូវសាសន៍ភីលីស្ទីនដណ្តើមយកបាន គាត់ក៏ដួលបាក់កស្លាប់ទៅ។

## សាសន៍ភីលីស្ទីនដណ្តើមហឹបសញ្ញា ពីសាសន៍អ៊ីស្រាអែល

ជំពូក៤ សម្តែងអំពីភាពខ្មៅងងឹត ដែលគ្របដណ្តប់មកលើជនជាតិអ៊ីស្រាអែល។ កម្រិតនៃការចេះដឹងខាងវិញ្ញាណរបស់សាសន៍នេះ ត្រូវចុះទន់ខ្សោយយ៉ាងខ្លាំង។ ចំណែកឯព្រះជាម្ចាស់វិញ ទ្រង់នឹងសម្រេចសេចក្តីដែលទ្រង់មានបន្ទូលរួចហើយថា ទ្រង់នឹងជំនុំជំរះដល់លំនៅដ្ឋានរបស់សង្ឃអេលី។

**១ រីឯសាសន៍អ៊ីស្រាអែល គេលើកគ្នាចេញទៅច្បាំងនឹងពួកសាសន៍**
**ភីលីស្ទីន បោះទ័ពនៅជិតអេបេន-អេសើរ ឯពួកភីលីស្ទីន ក៏បោះ**
**ទ័ពនៅត្រង់អាផែក ២ ពួកភីលីស្ទីនគេដំរៀបទ័ពប្រទល់នឹងអ៊ីស្រា**
**អែល រួចកាលគេបានចូលប្រឡូកតដៃគ្នា នោះពួកអ៊ីស្រាអែលចាក់**
**ចាញ់នៅមុខគេ ហើយគេវាយសំឡាប់ពលទ័ពនៅវាល អស់**
**ប្រហែលជា៤ពាន់នាក់ ៣ ដូច្នេះកាលពួកពលបានចូលមកក្នុងទី**
**បោះទ័ពវិញ នោះពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលជំនុំគ្នាថា**
**ហេតុអ្វីបានជាព្រះយេហូវ៉ាទ្រង់វាយយើង នៅចំពោះមុខពួក**
**ភីលីស្ទីនក្នុងថ្ងៃនេះដូច្នេះ ចូរយើងនាំយកហឹបនៃសញ្ញារបស់ព្រះ**
**យេហូវ៉ា ពីស៊ីឡូរមកឯយើង ដើម្បីឱ្យនៅកណ្តាលពួកយើង**

**ហើយជួយសង្គ្រោះយើង ពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ (១សាំយូអែល៤: ១-៣)។**

អត្ថបទខាងលើសម្ដែងអំពីសាសន៍អ៊ីស្រាអែលជឿលើពាក្យទំនឹមទំនៀម ជាជាងជឿដល់ព្រះបន្ទូលរបស់ព្រះ។ កិរិយារបស់គេឃ្លាតឆ្ងាយពីព្រះជាម្ចាស់ហើយ។ គេជឿទុកចិត្តលើខ្លួនឯង ព្រមទាំងចិត្តមានះថែមទៀតផង។ គេយល់ថា តើចាំបាច់សួរព្រះជាម្ចាស់បានប្រយោជន៍អ្វី បើចង់ធ្វើសង្គ្រាម ចូរយើងទៅទាស់ជាមួយនឹងសាសន៍ភីលីស្ទីនតែម្ដងទៅ។ ដោយសារគេមិនបានទូលសួរយោបល់ដល់ព្រះជាម្ចាស់ គេក៏ទទួលបរាជ័យមែន។ ហេតុអ្វីបានជាសាសន៍អ៊ីស្រាអែលទទួលបរាជ័យ? គេទទួលបរាជ័យ ពីព្រោះគេយល់ថា គេមានហឹបសញ្ញារបស់ព្រះជាម្ចាស់ជាវត្ថុស័ក្តសិទ្ធិសម្រាប់គេនៅក្នុងសង្គ្រាម។ ហឹបសញ្ញាមិនមែនជាវត្ថុស័ក្តសិទ្ធិទេ។ ពួកសាសន៍អ៊ីស្រាអែលនាំគ្នាចាប់ព្រះដាក់ក្នុងប្រអប់ រួចហើយសែងយកទៅធ្វើសង្គ្រាម។ លោកអ្នកមិនអាចចាប់ព្រះដាក់ក្នុងប្រអប់គំនិតរបស់លោកអ្នកបានទេ។ អំណាចចេស្ដាមិនមែនស្ថិតនៅលើហឹបសញ្ញាឡើយ អំណាចចេស្ដានៃហឹបសញ្ញាស្ថិតនៅលើវត្តមានរបស់ព្រះជាម្ចាស់ដែលគង់ជាមួយវិញ។

នៅក្នុងក្រុមជំនុំរបស់ព្រះសព្វថ្ងៃក៏ដូច្នោះដែរ។ គ្រីស្ទបរិស័ទខ្លះបានបង្កើតវត្ថុស័ក្តសិទ្ធិជាច្រើនដាក់នៅក្នុងក្រុមជំនុំរបស់គេ។ គេគិតថា បើគេចាប់ព្រះដាក់នៅក្នុង

ប្រអប់ជាវត្ថុស័ក្តសិទ្ធិរបស់គេ នោះព្រះជាម្ចាស់ពិតជាផ្តល់គន្លឹះសម្រាប់អោយគេបានជោគជ័យជាមិនខាន។ គេយល់ថា ដើម្បីអធិស្ឋាន គេត្រូវទន្ទ្រាំជើងទាញមេឃទម្លាក់ទើបព្រះជាម្ចាស់ឆ្លើយ។ គេចាប់ព្រះយកមកដាក់ក្នុងប្រអប់របៀបអធិស្ឋានរបស់គេ។ អ្នកខ្លះយល់ថា ត្រូវថ្វាយបង្គំព្រះរបៀបនេះ ឬរបៀបនោះ ទើបព្រះជាម្ចាស់គង់នៅជាមួយ។ គេចាប់ព្រះដាក់នៅក្នុងប្រអប់នៃគំនិតរបស់គេ ស្តីអំពីវិធីថ្វាយបង្គំ។ លោកអ្នកបងប្អូនអើយ មានរឿងដទៃៗទៀតជាច្រើន ដែលគេយល់ថា គេចាប់ព្រះជាម្ចាស់ដាក់នៅក្នុងប្រអប់ ដើម្បីអោយគេបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ រឿងនោះ មិនមែនជារឿងទាក់ទងខាងព្រលឹងវិញ្ញាណទេ។ រឿងនោះ គ្រីស្ទបរិស័ទនាំគ្នាបង្កើតវត្ថុស័ក្តសិទ្ធិនៅក្នុងវិហាររបស់ខ្លួនហើយ។ ឯវត្ថុស័ក្តសិទ្ធិនោះទៀតសោត គឺជារូបព្រះដែលតាំងនៅក្នុងព្រះវិហាររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ តើភាពស័ក្តសិទ្ធិទទួលបានមកពីអ្វីវិញ? ភាពស័ក្តសិទ្ធិបានមកពីវត្តមានរបស់ព្រះគ្រីស្ទគង់ជាមួយនឹងរាស្ត្ររបស់ទ្រង់។ ជ័យជំនះរបស់លោកអ្នកក្នុងការបម្រើព្រះ មិនមែនស្ថិតនៅលើវិធី មិនមែនស្ថិតនៅលើប្រព័ន្ធ មិនមែនស្ថិតនៅលើអ្វីៗ ដែលលោកអ្នកធ្វើជាប្រអប់ចាប់ព្រះមកដាក់នៅក្នុងប្រអប់នោះទេ។ ជ័យជំនះរបស់យើងស្ថិតនៅលើទំនាក់ទំនងរវាងយើង ជាមួយនឹងព្រះអម្ចាស់យេស៊ូវរៀងរាល់ថ្ងៃ។ ទំនាក់ទំនងប្រកបដោយតម្លាភាព រវាងគ្រីស្ទបរិស័ទនិងព្រះអម្ចាស់យេស៊ូវ រាប់ថាជាកត្តាសំខាន់សម្រាប់អោយយើងមានជ័យជំនះក្នុងការបម្រើទ្រង់។

**៤នោះគេក៏ចាត់ឱ្យទៅឯស៊ីឡូរ នាំយកហឹបនៃសេចក្តីសញ្ញា ផង
ព្រះយេហូវ៉ានៃពួកពលបរិវារ ដែលនៅកណ្តាលចេរូប៊ីន ពីទីនោះ
មក ឯហុបនី នឹងភីនេហាស ជាកូនអេលីទាំង២ ក៏នៅទីនោះ
ជាមួយនឹងហឹបនៃសេចក្តីសញ្ញារបស់ព្រះដែរ ៥កាលហឹបនៃ
សេចក្តីសញ្ញារបស់ព្រះយេហូវ៉ា បានមកដល់ក្នុងទីបោះទ័ពហើយ
នោះស្រាប់តែពួកអ៊ីស្រាអែលទាំងអស់គ្នា គេស្រែកឡើងជាខ្លាំង
ដល់ម៉្លេះបានជាឮខ្ទរខ្ទារនៅផែនដី (១សាំយូអែល៤:៤-៥)។**

សាសន៍អ៊ីស្រាអែលគេនាំគ្នាថ្វាយបង្គំហឹបសញ្ញា ពោលគឺគេមិនបានថ្វាយបង្គំព្រះជាម្ចាស់ទេ។ រីឯសង្ឃហុបនី និងភីនេហាស គ្រាន់តែជាគ្រូគង្វាលដែលគេបង់លុយអោយធ្វើការដល់ពួកជំនុំប៉ុណ្ណោះ។ ដូច្នេះ កាលណាពួកចាស់ទុំអោយធ្វើអ្វី គេចេះតែធ្វើទៅ មិនដឹងថាខុសឬត្រូវទេ។ គេយល់ថា បើសិនជាគេសែងហឹបសញ្ញាជាវត្ថុស័ក្តសិទ្ធិចូលទៅក្នុងសង្គ្រាម គេពិតជាឈ្នះសង្គ្រាមជាមិនខាន។ ប៉ុន្តែ លោកអ្នកបងប្អូនអើយ ការចាប់ដាក់នៅក្នុងប្រអប់ គឺជាការថ្វាយបង្គំរូបព្រះ។ ខ្ញុំសូមសួរដល់លោកអ្នកបងប្អូនបន្តិចនៅថ្ងៃនេះថា តើលោកអ្នកកំពុងថ្វាយបង្គំក្រុមជំនុំរបស់លោកអ្នកឬ? តើលោកអ្នកកំពុងថ្វាយបង្គំមនុស្សណាម្នាក់ ដែលលោកអ្នកយល់ថាជាអ្នកដឹកនាំគ្រីស្ទបរិស័ទសំខាន់ជាងគេឬ? តើលោកអ្នកកំពុងថ្វាយបង្គំពិធីណាមួយឬ? តើលោកអ្នកកំពុងថ្វាយបង្គំកន្លែងណាមួយ ដែលលោកអ្នកយល់ថាជាកន្លែងបរិសុទ្ធឬ? ឬមួយលោក

អ្នកកំពុងថ្វាយបង្គំដល់ព្រះដ៏រស់ គឺព្រះជាម្ចាស់ជាព្រះដ៏ពិត?

> **៦ លុះពួកភីលីស្ទីនបានឮស្នូរសព្ទសំរែកដូច្នោះ ក៏សួរគ្នាថា តើស្នូរ
> សព្ទសំរែកជាខ្លាំងដល់ម៉្លេះ នៅទីបោះទ័ពរបស់ពួកសាសន៍
> ហេព្រើរជាយ៉ាងណាហ្ន៎ នោះក៏យល់ឃើញថា ហឹបនៃព្រះ
> យេហូវ៉ាបានមកដល់ទីបោះទ័ពហើយ ៧ ដូច្នេះ ពួកភីលីស្ទីនមាន
> សេចក្តីភ័យ ដោយថា ព្រះបានយាងមកក្នុងទីបោះទ័ពគេហើយ
> រួចក៏ថា វរហើយ យើងរាល់គ្នា ដ្បិតកាលពីដើមមិនដែលមាន
> ដូច្នេះឡើយ ៨ វរហើយ យើងរាល់គ្នា តើមានអ្នកណានឹងជួយ
> យើង ឲ្យរួចពីកណ្តាប់ដៃនៃព្រះដ៏ខ្លាំងពូកែទាំងនេះ គឺព្រះទាំង
> ប៉ុន្មាននេះហើយ ដែលបានវាយពួកសាសន៍អេស៊ីព្ទនៅទីរហោ
> ស្ថាន ដោយសេចក្តីវេទនាគ្រប់យ៉ាង (១សាំយូអែល៤:៦-៨)។**

ពួកសាសន៍ភីលីស្ទីនដឹងថា សាសន៍អ៊ីស្រាអែលសែងហឹបសញ្ញារបស់ព្រះគេមកជាមួយផង។ គេមានការភ័យខ្លាចយ៉ាងខ្លាំង។ ចំពោះសាសន៍ភីលីស្ទីន ហឹបសញ្ញាគឺជារូបព្រះតែប៉ុណ្ណោះ។ គេដឹងថាហឹបសញ្ញាជានិមិត្តរូបនៃវត្តមានរបស់ព្រះដ៏ពិត និងព្រះដ៏រស់។ ប៉ុន្តែ គេនៅតែជឿលើពាក្យទំនឹមទំនៀមថា ហឹបសញ្ញានេះ ជាវត្ថុស័ក្តសិទ្ធិដូចសាសន៍អ៊ីស្រាអែលដែរ។

## សង្ឃអេលីចូលទីវង្គត រីឯសិរីល្អរបស់ព្រះ
## ក៏ចាកចេញពីពួកអ៊ីស្រាអែល

សាសន៍ភីលីស្ទីនបានយកជ័យជំនះលើសាសន៍អ៊ីស្រាអែល នៅក្នុងសមរភូមិ ព្រមទាំងសម្លាប់សាសន៍អ៊ីស្រាអែលបានជាច្រើនផង។ មិនតែប៉ុណ្ណោះ សាសន៍ភីលីស្ទីន នាំគ្នាដណ្ដើមហឹបសញ្ញារបស់ព្រះយកទៅជាមួយ។ រីឯកូនប្រុសទាំងពីររូបរបស់សង្ឃ អេលី គឺលោកហុបនី និងលោកភីនេហាសបានត្រូវស្លាប់នៅក្នុងសមរភូមិដែរ។

**[១២]នៅថ្ងៃនោះឯង មានពួកបេនយ៉ាមីនម្នាក់រត់ពីទីចំបាំង ទៅឯ
ស៊ីឡូរ មានសំលៀកបំពាក់រហែករហូរ ហើយមានដីនៅលើក្បាល
ផង [១៣]កាលគាត់ចូលទៅដល់ នោះអេលីកំពុងអង្គុយទន្ទឹងចាំនៅ
មាត់ផ្លូវ ដ្បិតលោកមានចិត្តភ័យញ័រ ដោយព្រោះហឹបនៃព្រះជា
ខ្លាំង កាលអ្នកនោះបានចូលមកប្រាប់ដំណឹងដល់ពួកទីក្រុង នោះ
គេស្រែកឡើងទាំងអស់គ្នា (១សាំយូអែល៤:១២-១៣)។**

សង្ឃអេលី ទោះបីលោកមានកំហុសខ្លះមែន លោកពិតជាសង្ឃរបស់ព្រះ មែន។ លោកគិតគូរដល់កិត្តិនាមរបស់ព្រះជាម្ចាស់ណាស់។

**១៤ឯអេលី ក៏ឮសូរសព្ទសំរែកនោះ ហើយសួរថា តើសូរសព្ទអឹង**
**កងដែលឮមកនេះ ដោយហេតុអ្វី ដូច្នេះអ្នកនោះក៏ចូលមកជា**
**ប្រញាប់ជំរាបដល់អេលី ១៥រីឯអេលីលោកមានអាយុ៩៨ឆ្នាំហើយ**
**ភ្នែកលោកក៏ងងឹត មើលអ្វីមិនឃើញឡើយ ១៦អ្នកនោះជំរាបថា**
**គឺខ្ញុំនេះ ដែលចេញមកពីទីចំបាំង ខ្ញុំបានរត់រួចនៅថ្ងៃនេះឯង**
**អេលីសួរថា កូនអើយ ចុះតើយ៉ាងដូចម្តេចទៅ (១សាំយូអែល៤:**
**១៤-១៦)។**

នៅពេលដែលសង្ឃអេលីដឹងថា សាសន៍អ៊ីស្រាអែលចាញ់សង្គ្រាម លោកចង់ដឹងអំពីមូលហេតុអោយបានពិតប្រាកដ។

**១៧អ្នកដែលនាំដំណឹងមកក៏ឆ្លើយថា ពួកអ៊ីស្រាអែលយើងបានរត់**
**ពីចំពោះពួកភីលីស្ទីនចេញ មានពលទ័ពខាងយើងស្លាប់អស់សន្ធឹក**
**ហើយហុបនី នឹងភីនេហាស កូនលោកទាំង២ក៏ស្លាប់ទៅដែរ**
**ឯហឹបនៃព្រះ គេក៏បានចាប់យកទៅហើយ ១៨កាលអ្នកនោះ**
**ដំណាលពីហឹបនៃព្រះដូច្នោះ នោះស្រាប់តែអេលី លោកផ្ងារធ្លាក់**
**ចុះពីជើងម៉ា ជាទីដែលលោកអង្គុយនៅត្រង់មាត់ទ្វារនោះ បាក់ក**
**ស្លាប់ទៅ ដ្បិតមានអាយុច្រើន ហើយក៏ធ្ងន់ផង លោកបានគ្រប់**

**គ្រងលើសាសន៍អ៊ីស្រាអែលអស់៤០ឆ្នាំ (១សាំយូអែល៤:១៧-១៨)។**

នៅពេលដែលលោកដឹងថា កូនប្រុសរបស់លោកទាំងពីរត្រូវស្លាប់នៅក្នុងសមរភូមិ លោកមានការតក់ស្លុតខ្លាំងល្មមទេ។ ប៉ុន្តែ នៅពេលដែលដឹងថា ហឹបសញ្ញារបស់ព្រះជាម្ចាស់ត្រូវគេដណ្តើមបាន លោកក៏ដួលបាក់កស្លាប់ទៅ។ ទោះបីសង្ឃអេលីជាមនុស្សទន់ខ្សោយ លោកពិតជាមនុស្សសំណព្វរបស់ព្រះជាម្ចាស់មែន។ បន្ទាប់ពីសង្ឃអេលីស្លាប់ទៅ ព្រះជាម្ចាស់តែងតាំងសាំយូអែលអោយធ្វើជាហោរារបស់ព្រះអង្គ ពោលគឺជាអ្នកដែលពាំនាំព្រះបន្ទូលពីព្រះជាម្ចាស់មកដល់មនុស្សលោក។

# ជំពូក ៥

***ធាតុផ្សំ** ការជំនុំជំរះដល់សាសន៍ភីលីស្ទីន*

ជំពូក៥និងជំពូក៦ សម្តែងអំពីបទពិសោធន៍របស់សាសន៍ភីលីស្ទីន ជាមួយនឹងហឹបសញ្ញារបស់ព្រះជាម្ចាស់។ ដោយសារសាសន៍ភីលីស្ទីនជួបប្រទះជាមួយនឹងគ្រាកលយុគជាច្រើន បានជាគេបញ្ជូនហឹបសញ្ញាមកអោយសាសន៍អ៊ីស្រាអែល។

**[១]រីឯពួកភីលីស្ទីន គេចាប់យកបានហឹបនៃព្រះ រួចក៏នាំយកចេញពី**
**អេបេន-អេស៊ើរ ទៅឯក្រុងអាសដូឌទៅ [២]ហើយគេយកទៅដាក់**
**ក្នុងវិហារនៃព្រះដាកុន គឺនៅក្បែរព្រះនោះ [៣]លុះស្អែកឡើង កាល**
**ពួកក្រុងអាសដូឌបានក្រោកឡើងពីព្រលឹម នោះក៏ឃើញព្រះ**
**ដាកុនបានដួលផ្កាប់មុខដល់ដី នៅចំពោះហឹបនៃព្រះយេហូវ៉ា រួច**
**គេលើកព្រះដាកុន ទៅដាក់នៅកន្លែងដើមវិញ [៤]លុះដល់ថ្ងៃស្អែក**
**ទៀត កាលគេក្រោកពីព្រលឹម នោះក៏ឃើញព្រះដាកុនបានដួល**
**ផ្កាប់មុខដល់ដី នៅចំពោះហឹបនៃព្រះយេហូវ៉ាទៀត ហើយក្បាល**
**នឹងដៃទាំង២នៃព្រះដាកុន ក៏បាក់ដាច់ នៅលើក្របទ្វារ សល់នៅ**
**តែតួព្រះដាកុនប៉ុណ្ណោះ (១សាំយូអែល៥:១-៤)។**

នៅពេលសាសន៍ភីលីស្ទីនដណ្ដើមបានយកហឹបសញ្ញា គេយកទៅដាក់នៅក្នុងវិហាររបស់គេ ក្បែររូបព្រះដាកុន។ លុះព្រលឹមឡើង គេឃើញរូបព្រះដាកុនរបស់គេ ត្រូវដួលបាក់កទាំងអស់។ ចំណុចនេះ ព្រះជាម្ចាស់បើកសម្ដែងអោយសាសន៍ភីលីស្ទីនដឹងថា ព្រះយេហូវ៉ាមានចេស្ដាលើសលប់ខ្លាំងជាងរូបព្រះនានា។

> **៦ឯព្រះហស្តនៃព្រះយេហូវ៉ា ក៏សង្កត់លើពួកក្រុងអាសដូឌយ៉ាង
> ធ្ងន់ ទ្រង់បំផ្លាញគេ ហើយវាយគេដោយរោគឫសដូងបាត នៅ
> ក្រុងអាសដូឌ នឹងស្រុកជុំវិញទាំងអស់ ៧កាលពួកអាសដូឌឃើញ
> ថា កើតមានយ៉ាងដូច្នោះ នោះគេជំនុំគ្នាថា មិនត្រូវឱ្យហឹបនៃ
> ព្រះរបស់សាសន៍អ៊ីស្រាអែលនៅជាមួយនឹងយើងទៀតឡើយ ដ្បិត
> ព្រះហស្តនៃទ្រង់សង្កត់លើយើងរាល់គ្នាធ្ងន់ណាស់ ហើយលើព្រះ
> ដាកុនជាព្រះនៃយើងដែរ (១សាំយូអែល៥:៦-៧)។**

ពួកសាសន៍ភីលីស្ទីនបញ្ជូនហឹបសញ្ញាទៅដល់ទីក្រុងមួយទៀត នៅក្នុងទឹកដីរបស់ខ្លួន។

> **៨ដូច្នេះគេក៏ចាត់ឱ្យទៅ ប្រមូលពួកមេនៃសាសន៍ភីលីស្ទីនទាំង
> ប៉ុន្មានមកជំនុំគ្នាថា តើត្រូវឱ្យយើងធ្វើដូចម្តេចនឹងហឹបព្រះ របស់**

**សាសន៍អ៊ីស្រាអែលនេះ គេឆ្លើយថា ចូរនាំយកទៅឯក្រុងកាថទៅ
ដូច្នេះ គេក៏នាំយកហឹបនៃព្រះរបស់សាសន៍អ៊ីស្រាអែល ទៅឯទី
នោះ ៩កាលគេបាននាំយកទៅឯណោះហើយ នោះព្រះហស្តនៃ
ព្រះយេហូវ៉ាក៏ទាស់នឹងទីក្រុងនោះ ដោយសេចក្តីវេទនាយ៉ាងខ្លាំង
ដែរ ទ្រង់វាយពួកក្រុងនោះទាំងតូចទាំងធំ ឱ្យកើតមានឫសដូង
បាតទាំងអស់គ្នា ១០ដូច្នេះ គេក៏នាំយកហឹបនៃព្រះទៅឯក្រុង
អេក្រុនទៀត កាលបានដល់អេក្រុនហើយ ពួកក្រុងនោះស្រែក
ឡើងថា គេបានយកហឹបនៃព្រះរបស់សាសន៍អ៊ីស្រាអែលមកឯ
យើង ដើម្បីនឹងសំឡាប់យើង នឹងពួកយើងផងហើយ (១សាំយូ
អែល៥:៨-១០)។**

ទីក្រុងណា ដែលគេបញ្ជូនហឹបសញ្ញាទៅ ទីក្រុងនោះទទួលរងគ្រោះដូចគ្នាទាំងអស់។ គេសួរគ្នាថា "តើយើងត្រូវធ្វើយ៉ាងដូចម្តេច ចំពោះហឹបសញ្ញារបស់សាសន៍អ៊ីស្រាអែល?"

យើងស្ទេះការសិក្សាគម្ពីរ១សាំយូអែលត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"